រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ: ០៨២/១១ ក.ប.ក.អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១១
## និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១១

(០១/៥/២០១១-៣១/៥/២០១១)

ខែឧសភាឆ្នាំ២០១១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមទិសដៅពហុវិស័យ ដែលបានដាក់ចេញកាលពីខែមេសាកន្លងទៅ ដើម្បីរួមចំណែកអនុវត្ត"គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានខិតខំអនុវត្តនៅក្នុងខែឧសភានេះ មានដូចតទៅ :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែឧសភាឆ្នាំ២០១១នេះ ពួកឈ្មួញគ្រឿងញៀនបានបន្តធ្វើសកម្មភាពនាំគ្រឿងញៀនពីតំបន់ព្រំដែនភាគពាយ័ព្យចូលមកក្នុងប្រទេស តាមរយៈខ្សែបណ្តាញជួញដូរគ្រឿងញៀននៅក្នុងស្រុក ដើម្បីលក់ចែកចាយនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តមួយចំនួន ហើយមួយចំនួនទៀតបានវេចខ្ចប់នាំចេញទៅប្រទេសជិតខាង ។ ក្នុងចំណោមគ្រឿងញៀនដែលបាននាំចូលមកកម្ពុជាតាមច្រកខាងលើនេះ យើងបានកត់សំគាល់ឃើញ មេតំហ្វេតាមីនគ្រាប់ (ស្លាកសញ្ញា WY) និងមេតំហ្វេតាមីនទឹកកក (ICE) ជាប្រភេទគ្រឿងញៀននាំមុខគេ ។ ដោយឡែក ហេរ៉ូអ៊ីន ត្រូវបានបណ្តាញរបស់ក្រុមឧក្រិដ្ឋជនជួញដូរគ្រឿងញៀនឆ្លងដែនមានការចាត់តាំង នាំឆ្លងកាត់ប្រទេសកម្ពុជាក្នុងទិសដៅនាំទៅកាន់ទីផ្សារគ្រឿងញៀនអន្តរជាតិ ព្រមទាំងនាំចូលឧបករណ៍សម្ភារៈ និងសារធាតុគីមីផ្សំដើម្បីផលិតកែច្នៃគ្រឿងញៀន តែត្រូវសមត្ថកិច្ចនៅរាជធានីភ្នំពេញបង្ក្រាបបាន ២ករណី, នៅខេត្តបន្ទាយមានជ័យ ១ករណី និងនៅខេត្តព្រះសីហនុ ១ករណី ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងខែឧសភាឆ្នាំ២០១១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្ត

ទុកដាក់លើកកម្ពស់វិធានការពហុវិស័យទាំង៥ ក្នុងការត្រួតពិនិត្យគ្រឿងញៀនដែលមានដូចតទៅ :

១- ការអនុញ្ញាតឱ្យតំណាងអង្គការសហប្រជាជាតិ ប្រធានវេទិកាដៃគូអភិវឌ្ឍន៍ស្តីពីបញ្ហាហ៊ីវ/អេដស៍ និងលោក នាយក ប្រតិបត្តិអង្គការ ខាណា ប្រចាំកម្ពុជា ចូលជួបពិភាក្សាការងារ (១១/៥/២០១១) ។

២- ការដឹកនាំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១ (៣១/៥-០១/៦/២០១១) ។

៣- ការអនុញ្ញាតជាគោលការណ៍ឱ្យក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមក្នុងកិច្ចប្រជុំ លើកទី៨ នៃគណៈកម្មាធិការស្វែងរកការពិត ដើម្បីប្រយុទ្ធប្រឆាំងការគំរាមកំហែងដោយគ្រឿងញៀន 8th AIFOCOM (២៥-២៩/៥/២០១១) ។

៤- ការអនុញ្ញាតឱ្យឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ ដឹកនាំប្រតិភូទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និង ថ្នាក់រដ្ឋមន្ត្រីនៃបណ្តាប្រទេសសមាជិក MOU នៅទីក្រុងវៀងច័ន្ទ (២២-២៥/៥/២០១១) ។

៥- ការណែនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យរៀបចំកិច្ចប្រជុំពិភាក្សាជាមួយតំណាងការិយាល័យអង្គការ UNODC អង្គការសុខភាពពិភពលោក, កម្មវិធីអេដស៍អង្គការសហប្រជាជាតិ និង អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ពាក់ព័ន្ធនឹងមូលនិធិសកលជុំទី១១ ។

៦- ការណែនាំ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យត្រៀមលក្ខណៈសម្បត្តិក្នុងការឆ្លើយបំភ្លឺជូនអង្គការUNAIDS ពីការព្រួយបារម្ភក្នុងការអនុវត្តកម្មវិធីបង្ការការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ នៅពេលដែលរាជរដ្ឋាភិបាលអនុវត្តគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

## ***១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន***

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំនិងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់, គ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈសកម្មភាព មានដូចជា :

-ការផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ស៊ីធីអិន-អ៊ីនធឺណេត ដោយតំណាងក្រសួងអប់រំយុវជននិងកីឡា ក្រោមប្រធានបទស្តីពី "ការទទួលខុសត្រូវក្នុងការអប់រំ និងបញ្ជ្រាបពីផលប៉ះពាល់ និងឥទ្ធិពលគ្រឿងញៀន" ដល់ស្រទាប់យុវវ័យ ជាពិសេសសិស្សានុសិស្ស (ថ្ងៃទី២៥ខែឧសភាឆ្នាំ២០១១) ។

-ការចូលរួមជាវាគ្មិន ក្នុងវគ្គបំផុសស្មារតីស្តីពី "ភាពជាដៃគូសហគមន៍ដើម្បីសុវត្ថិភាព ក្នុងការឆ្លើយតបការរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍" នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ (ថ្ងៃទី១២ខែឧសភាឆ្នាំ២០១១) ។

សកម្មភាពការងារទាំងអស់ខាងលើ រួមទាំងការងារផ្សព្វផ្សាយប្រចាំខែរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តនានា មានមន្ត្រីរាជការ និងប្រជាពលរដ្ឋចូលរួម សរុប **២៩.៩៨០** នាក់ (មានរាយលំអិតក្នុងទំព័រទី១០) បើធ្វើការប្រៀបធៀបខែមេសា ឆ្នាំ២០១១ ដែលមានអ្នកចូលរួមចំនួន **៤២.៦៣០** នាក់ គឺមានការថយចុះ ២៩,៦៧ % ។

## ២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

នៅក្នុងខែឧសភានេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និង គ្រប់លំដាប់ថ្នាក់ បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលខ្ពស់ ជាក់ស្តែង :

-បង្ក្រាបបទល្មើសគ្រឿងញៀនបាន **១៦២ ករណី** (ប្រៀបធៀបខែមេសា ឆ្នាំ២០១១ ដែលបទល្មើសបង្ក្រាបបាន **៩៥** ករណី គឺកើនឡើង ៧០,៥២ % ។

-ឃាត់ខ្លួនមនុស្ស **៤០៩ នាក់**(ប្រុស៣២២នាក់, ស្រី៨៧នាក់) ប្រៀបធៀបខែមេសា ឆ្នាំ២០១១ ឃាត់ខ្លួនមនុស្សចំនួន ២៥២ នាក់ គឺកើនឡើងចំនួន ៦២,៣០% ក្នុងនោះ ជនជាតិខ្មែរ ៣៨៨ នាក់(ប្រុស៣០៨នាក់/ស្រី៨០នាក់), វៀតណាម ១៧ នាក់(ប្រុស១០នាក់/ស្រី៧នាក់), ឡាវ ១ នាក់ (ប្រុស), ថៃ ១ នាក់ (ប្រុស), ចិន ១ នាក់(ប្រុស), កុងហ្គោ ១ នាក់(ប្រុស) ។

**វត្ថុតាងចាប់យក** រួមមាន : មេតំហ្វេតាមីនWY ៣.២១៦ គ្រាប់, មេតំហ្វេតាមីនICE ៦២៨,៦៩ ក្រាម, ហេរ៉ូអ៊ីន ១.០០០,៤៥ ក្រាម, អ៊ិចស្តាស៊ី ១.៣៦៣ គ្រាប់, សារធាតុគីមីផ្សំ ៥១,៦ គ.ក្រ និង ២៣ លីត្រ, ដើមកញ្ឆា ៣.៩៨២ ដើម, កញ្ឆាក្រៀម ២០០ គ.ក្រ ព្រមទាំងវត្ថុតាងផ្សេងទៀត (មានរាយលំអិតក្នុងទំព័រទី១១ និងទី១២) ។

ដោយឡែក សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)ប្រចាំខែឧសភាឆ្នាំ២០១១ សរុបមានចំនួន 3.290.625 គីឡូក្រាម(មានរាយលំអិតមុខសារធាតុគីមីនៅក្នុងទំព័រទី១៣) ។

## ៣.ការព្យាបាល ស្តារនីតិសម្បទា និង ការកាត់បន្ថយគ្រោះថ្នាក់

ចំពោះការងារព្យាបាលនិងស្តារនីតិសម្បទា ក្រសួងសុខាភិបាល បាននិងកំពុងរៀបចំបង្កើតយន្តការអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនតាមសហគមន៍ ដោយយកមន្ទីរពេទ្យឯកទេស ពេទ្យបង្អែក មន្ទីរពេទ្យស្រុក និងមណ្ឌលសុខភាពនានា ជាមូលដ្ឋានសម្រាប់ជួយសម្រួលឱ្យជនរងគ្រោះអាចទៅទទួលយកសេវាដោយងាយស្រួល និងកំពុងជួយពង្រឹងនិងផ្តល់សេវាសុខភាពចាំបាច់នានា ដល់មណ្ឌលបណ្តោះអាសន្នសម្រាប់បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា បានចេញប្រកាសចំនួនពីរគឺ :

១- ប្រកាស ស្តីពីការបង្កើតគណៈកម្មការដើម្បីកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិក្នុងដំណើរការអភិវឌ្ឍមជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២- ប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះ មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលមានការិយាល័យចំណុះចំនួន បួន គឺ ការិយាល័យរដ្ឋបាល និងផ្គត់ផ្គង់, ការិយាល័យបន្សាប និងព្យាបាល, ការិយាល័យស្តារនីតិសម្បទា និង ការិយាល័យសមាហរណកម្ម ។

ចំណែកអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ នៅថ្ងៃទី២០ខែមេសាឆ្នាំ២០១១ បានជួបពិភាក្សាការងារជាមួយតំណាងការិយា-

ល័យអង្គការUNODC , អង្គការសុខភាពពិភពលោក(WHO), កម្មវិធីអេដស៍អង្គការសហប្រជាជាតិ(UNAIDS), អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីពិភាក្សាជុំវិញបញ្ហាមូលនិធិសកលជុំទី១១និងបញ្ហាក្រុមការងារគ្រឿងញៀនអេដស៍ ។

ដោយឡែក ជាមួយបណ្ដាប្រទេសនៅក្នុងតំបន់ អាជ្ញាធរជាតិ(អ.ជ.ប.គ.ញ) បានចាត់បញ្ជូនមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន និងធ្វើការសម្របសម្រួលជូនក្រសួងពាក់ព័ន្ធ អង្គការដៃគូ ដូចជា ក្រសួងសុខាភិបាល (មន្ត្រីកម្មវិធីផ្លូវចិត្ត), មន្ត្រីកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ (HAARP), បុគ្គលិកអង្គការកសាង, អង្គការមិត្តសម្លាញ់អន្តរជាតិ, អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI), និងអង្គការខាន់ណា សរុបចំនួន ៨នាក់ ដើម្បីទៅចូលរួមសិក្ខាសាលាគម្រោង HAARP ប្រចាំតំបន់ នៅទីក្រុងបាងកក ប្រទេសថៃ (០៣-០៤/៥/២០១១) ។ គោលបំណងនៃអង្គសិក្ខាសាលា ទី១).គឺដើម្បីកាត់បន្ថយការចម្លង HIV/AIDS នៅក្នុងចំណោមអ្នកប្រើគ្រឿងញៀនដោយចាក់, ទី២).បង្កើនសមត្ថភាពនិងឆន្ទៈរបស់រដ្ឋាភិបាលនិងសហគមន៍ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់, ទី៣).ចំណេះដឹងជាមូលដ្ឋាន និងលក្ខខណ្ឌតម្រូវសម្រាប់ប្រព័ន្ធតាមដាននិងវាយតម្លៃ (នៅក្នុងតំបន់អាស៊ីអាគ្នេយ៍និងចិន) ។ ដោយឡែក កម្ពុជានឹងធ្វើការពិភាក្សាកម្រិតបច្ចេកទេស ក្នុងខែមិថុនាជាមួយបណ្ដាស្ថាប័នអង្គការ និងដៃគូអនុវត្តគម្រោងនានា ក្រោមកិច្ចសម្របសម្រួលពីគម្រោង HAARP ដើម្បី :

ក. ជំរុញឱ្យមានប្រព័ន្ធតាមដាននិងវាយតម្លៃថ្នាក់ជាតិ នៅអគ្គលេខាធិការដ្ឋាន អជបគញ នៅចុងឆ្នាំ ២០១១ នេះ ។

ខ. ធ្វើការជ្រើសរើសយកគំរូឯកភាពសម្រាប់ការគ្រប់គ្រង ចំនួនអ្នកប្រើគ្រឿងញៀនដោយចាក់ តាមការប្រើលេខកូដសម្គាល់ (UID) ។

គ. ស្នើសុំការពិភាក្សាបន្ថែមទៀតជាមួយភាគីចិន ពីការសិក្សាលក្ខណៈបច្ចេកទេសនៃការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងដកស្រង់បទពិសោធន៍ការងារបច្ចុប្បន្នកម្មនៃកម្មវិធីគ្រប់គ្រងទិន្នន័យ ចំពោះការប្រើប្រាស់ប្រព័ន្ធបណ្ដាញគេហ-ទំព័រ ដើម្បីគ្រប់គ្រងទិន្នន័យចំនួនអ្នកប្រើប្រាស់គ្រឿងញៀន ។

## *៤.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់*

ដើម្បីពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់ ឱ្យកាន់តែទទួលបានប្រសិទ្ធភាព អាជ្ញាធរជាតិ(អ.ជ.ប.គ.ញ) បាន :

-ចាត់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ទៅឧទ្ទេសនាមនៅក្នុងសិក្ខាសាលា ស្ដីពីការប្រើប្រាស់សម្ភារៈធ្វើតេស្ដគ្រឿងញៀន ដែលរៀបចំដោយអង្គការ JICA កាលពីថ្ងៃទី២៦/៥/២០១១ នៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងគោលបំណងបង្កើនសមត្ថភាពមន្ត្រីគយនិងរដ្ឋាករកម្ពុជា ក្នុងការត្រួតពិនិត្យរូបវន្តស្រាវជ្រាវរកគ្រឿងញៀនដែលធ្វើចរាចរ នាំចេញ នាំចូល ឆ្លងកាត់ព្រំដែនជាយថាហេតុ ។

-ចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១រូប ទៅចូលរួមប្រជុំលើកទី១ ជាមួយក្រុមការងារសម្របសម្រួលកម្ពុជា-វៀន នៅរដ្ឋបាលព្រៃឈើ កាលពីថ្ងៃទី១២/៥/២០១១ ។

ដោយឡែក ជាមួយបណ្ដាប្រទេសនៅក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បាន :

-ចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចំនួន ១ រូប និងសម្របសម្រួលជូនមន្ត្រីកងរាជអាវុធហត្ថលើផ្ទៃប្រទេស ១ រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តន៏ច្បាប់ត្រួតពិនិត្យគ្រឿងញៀន លើកទី១១ ក្នុងក្របខ័ណ្ឌនៃកម្មវិធី (ASEAN Training Awards) កាលពីថ្ងៃទី២៣-២៧/៥/២០១១ នៅប្រទេសសឹង្ហបុរី ។

### *៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានចូលរួមក្នុងសកម្មភាព ជាអាទិ៍ :

១- បានចាត់ថ្នាក់ដឹកនាំ អគ្គលេខាធិការដ្ឋាន, ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ នៃអគ្គលេខាធិការដ្ឋាន អជបគញ ចំនួន ៤រូប និងសម្របសម្រួលជូន អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ១រូប, អគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ១រូប, មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ១រូប និងតំណាងស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសឡាវ ទៅចូលរួមកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ និងថ្នាក់រដ្ឋមន្ត្រី MOU ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងវៀងចន្ទ៍ កាលពីថ្ងៃទី២១-២៤ខែឧសភាឆ្នាំ២០១១ ក្រោមការដឹកនាំប្រតិភូដោយ ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

២- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១រូប ទៅចូលរួមសិក្ខាសាលាស្តីពីការអង្កេតការជួញដូរទេសន្តប្រវេសន៍ កាលពីថ្ងៃទី១០-១២/៥/២០១១ នៅប្រទេសវៀតណាម ដោយអង្គការ UNODC មានគម្រោងនឹងដាក់ឱ្យដំណើរការនូវកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិកត្រូនិក នូវជំនាញទប់ស្កាត់ការជួញដូរទេសន្តរប្រវេសន៍ សម្រាប់មន្ត្រី BLO ជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា ម៉ាឡេស៊ី និង ឥណ្ឌូនេស៊ី ។

៣- ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) បានសម្រេចផ្តល់សម្ភារៈចាំបាច់ជាមូលដ្ឋានសម្រាប់កិច្ចប្រតិបត្តិការរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ២ កន្លែងនៅ ច្រកទ្វារអន្តរជាតិភ្នំដិន (ខេត្តតាកែវ) និងច្រកទ្វារអន្តរជាតិ ត្រពាំងផ្លុង (ខេត្តកំពង់ចាម) ។

៤- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមក្នុងកិច្ចប្រជុំលើកទី១១ នៃមន្ត្រីសម្របសម្រួលអន្តរជាតិដើម្បីកិច្ចសហប្រតិបត្តិការប្រឆាំងទៅនឹងគ្រឿងញៀន (Anti-Drug Liaison Officials' Meeting for International Cooperation (ADLOMICO) កាលពីថ្ងៃទី ១៦ ដល់ ១៩ ខែឧសភា ឆ្នាំ២០១១ នៅសាធារណរដ្ឋកូរ៉េ ។ កិច្ចប្រជុំនេះ ត្រូវបានចែកចេញជា ២ កិច្ចប្រជុំទៀតដូចខាងក្រោម :

a- កិច្ចប្រជុំបណ្តាប្រទេសអាស៊ាន+កូរ៉េ ដោយបានពិភាក្សាគ្នាអំពីកិច្ចដំណើរការរបស់ "មជ្ឈមណ្ឌលសម្របសម្រួលព័ត៌មានប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក" (Asia Pacific Information & Coordination Center . APICC) សម្រាប់ប្រយុទ្ធប្រឆាំងទៅនឹងគ្រឿងញៀននិងឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់, ពិភាក្សាលើអនុស្សារណៈនៃការយោគយល់គ្នារបស់មជ្ឈមណ្ឌលសម្របសម្រួលព័ត៌មានប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក, ពិភាក្សាអំពីប្រព័ន្ធទិន្នន័យ

ដែលត្រូវប្រើប្រាស់សម្រាប់ការបញ្ជូនព័ត៌មានឱ្យគ្នាទៅវិញទៅមក និងបានឯកភាពគ្នាលើផែនការសកម្មភាពមួយចំនួន ដោយធ្វើការបែងចែកទៅតាមប្រទេស និងគោលដៅអនុវត្តដូចខាងក្រោម :

-ជំហានទី១ ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ជាប្រទេសដែលទទួលលើ ការងារយុទ្ធនាការឃោសនាផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន, ការគាំទ្រសម្ភារៈ និងបច្ចេកទេសសម្រាប់ការស៊ើបអង្កេត និងការផ្ទេរបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកដល់មន្ត្រីអនុវត្តច្បាប់ ។

-ជំហានទី២ ប្រទេស ហ្វីលីពីន វៀតណាម ឥណ្ឌូនេស៊ី ជាប្រទេសដែលទទួលលើ ការងារផ្ទេរសមត្ថភាពជំនាញស៊ើបអង្កេតឱ្យគ្នាទៅវិញទៅមក, បច្ចេកទេសវិភាគគ្រឿងញៀន, ការគាំទ្រសម្ភារៈ បច្ចេកទេសសម្រាប់វិភាគគ្រឿងញៀន និងការរៀបចំបណ្តាញព័ត៌មានគ្រឿងញៀន ។

-ជំហានទី៣ ប្រទេស ថៃ សឹង្ហបុរី ប្រ៊ុយណេ ម៉ាឡេស៊ី ជាប្រទេសដែលទទួលលើ ការផ្ទេរជំនាញវិភាគគ្រឿងញៀន និងការគាំទ្រសម្ភារៈសម្រាប់វិភាគភស្តុតាង ឌីជីថល ។

b- កិច្ចប្រជុំពេញអង្គរបស់ ADLOMICO : តាមរយៈការលើកឡើងពីសកម្មភាពគ្រឿងញៀនទូទាំងតំបន់និងពិភពលោក ដោយបណ្តាប្រទេសដែលបានចូលរួម អង្គប្រជុំបានធ្វើការកត់សំគាល់ពីសភាពការណ៍វិវត្តប្រែប្រួលនៃបញ្ហាគ្រឿងញៀនមួយចំនួន ។ ក្នុងឱកាសនោះដែរ ប្រតិភូកម្ពុជាបានជួបពិភាក្សាការងារដោយឡែកជាមួយតំណាងអគ្គរដ្ឋអាជ្ញាកូរ៉េ និងតំណាងទីភ្នាក់ងារសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ ទទួលបានលទ្ធផលគួរកត់សំគាល់ ដោយផ្តោតសំខាន់ទៅលើផ្នែកមួយចំនួនដូចជា ការតភ្ជាប់បណ្តាញព័ត៌មានគ្រឿងញៀននិងឧក្រិដ្ឋ-កម្មនានានៅកម្ពុជា, ការឃោសនាផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការបោះពុម្ពឯកសារ, ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា ទាំងនៅក្នុងប្រទេស ទាំងនៅប្រទេសកូរ៉េ, ការគាំទ្រដល់មន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ការជួយគាំទ្រសម្រាប់ការធ្វើផែនការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅអំពីការអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង៥ខាងលើ អាជ្ញាធរជាតិ( អ.ជ.ប.គ.ញ) បានយកចិត្តទុកដាក់ជំរុញលើការងារមួយចំនួនទៀត ជាអាទិ៍ :

- បន្តអនុវត្តអនុសាសន៍ណែនាំ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដែលបានដាក់ចេញនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល និងដកពិសោធន៍ លើការអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន នៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១១ និងអនុសាសន៍ណែនាំនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន នៅខេត្តភាគឦសាន ដែលបានធ្វើនៅខេត្តស្ទឹងត្រែងកាលពីថ្ងៃទី០៦-០៧ ខែមេសា ឆ្នាំ២០១១ ។
- បន្តអនុវត្តអនុសាសន៍ណែនាំ របស់ឯកឧត្តម ស ខេង ឧបយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានដាក់ចេញនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១០ និងទិសដៅការងារ ឆ្នាំ២០១១ កាលពីថ្ងៃទី៣១ ខែឧសភា ដល់ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១ ។
- ការបន្តកិច្ចសហការជាមួយអង្គការ KHANA ក្នុងការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ដើម្បីអាចបំពេញតួនាទី ភារកិច្ច របស់ខ្លួនកាន់តែមានប្រសិទ្ធភាព ជាពិសេស លើការងារគ្រប់គ្រងទិន្នន័យព័ត៌មានគ្រឿងញៀនតាមលក្ខណៈវិទ្យាសាស្ត្រ ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

ក្នុងខែឧសភានេះ ដោយមានកិច្ចសហការល្អពីក្រសួងសមាជិក ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក៏ដូចជាពីគ្រប់មជ្ឈដ្ឋានសង្គម អាជ្ញាធរជាតិ( អ.ជ.ប.គ.ញ) បានបន្តអនុវត្តយុទ្ធសាស្ត្រពហុវិស័យ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងនោះ ៖

ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននិងអេដស៏ អាជ្ញាធរជាតិ( អ.ជ.ប.គ.ញ) បានបង្កើនការផ្សព្វផ្សាយអប់រំ ប៉ុន្តែតាមរយៈសកម្មភាពផ្សព្វផ្សាយនេះ យើងបានវាយតម្លៃថា នៅមិនទាន់បានជ្រួតជ្រាបទូលំទូលាយទៅដល់គោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ មានដូចជា ក្រុមសិស្សមិនចូលសាលារៀន ពលករចំណាកស្រុក កម្មករនៅតាមការដ្ឋាន ក្រុមអ្នកបម្រើការតាមផ្ទះសំណាក់ សណ្ឋាគារ ខារ៉ាអូខេ និងកន្លែងកម្សាន្តផ្សេងៗ ជាដើម ។

ជាមួយនេះដែរ អនុវត្តតាមគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានខិតខំប្រឹងប្រែងក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ធ្វើឱ្យទទួលបានលទ្ធផលគួរកត់សំគាល់ ។ ប៉ុន្តែបញ្ហាប្រឈមគឺការយល់ដឹងពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនរបស់មន្ត្រីអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋាននៅមានកម្រិត នៅមិនទាន់សិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ពីអត្តសញ្ញាណគ្រឿងញៀន ជាពិសេស នីតិវិធីក្នុងការកសាងសំណុំរឿង ការចោទប្រកាន់ និងភស្តុតាងរឹងសម្រាប់ការកំណត់ទម្ងន់ទោសជនល្មើសគ្រឿងញៀន ។

ការព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន យើងបាននិងកំពុងពង្រឹងសមត្ថភាពក្នុងការផ្តល់សេវាថែទាំ និងព្យាបាលតាមបែបវេជ្ជសាស្ត្រ ដល់មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ធ្វើឱ្យកាន់តែមានភាពសមស្របនិងល្អប្រសើរជាងមុន ។ ប៉ុន្តែយើងកំពុងប្រឈមនឹងដំណោះស្រាយ ចំពោះអ្នកក្រោមឥទ្ធិពលគ្រឿងញៀនដែលត្រូវការសម្រាកថែទាំសុខភាពរយៈពេលយូរ ដើម្បីថែទាំផ្នែកសុខភាពផ្លូវចិត្ត និងការកើនឡើងនូវចំនួនអ្នកប៉ះពាល់គ្រឿងញៀន ដែលអាជ្ញាធរមានសមត្ថកិច្ចបញ្ជូនមកនៅពេលអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ។ ជាមួយគ្នានេះ ការអនុវត្តកម្មវិធីព្យាបាលតាមសហគមន៍ ដើម្បីជួយដោះបន្ទុកមណ្ឌលបណ្តោះអាសន្នដែលមានសព្វថ្ងៃ គឺមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយ ។

យើងបានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគី-ពហុភាគី បានច្រើនជាមួយបណ្តាអង្គការនិងប្រទេសជាដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែយើងនៅមិនទាន់ទទួលបាននូវលទ្ធផលមកវិញឱ្យបានពេញលេញពីបណ្តាគម្រោងទាំងអស់នោះនៅឡើយ ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១១

ដូចដែលបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តន៍យុទ្ធសាស្ត្រពហុវិស័យទាំង៥ ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តបន្តដូចខាងក្រោម :

១. អ.ជ.ប.គ.ញ នឹងបន្តកិច្ចសហការ សម្របសម្រួលជាមួយក្រសួងជាសមាជិក និងក្រសួង-ស្ថាប័នពាក់ ព័ន្ធនានា, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងកម្លាំងសរុបរបស់សង្គម អនុវត្តការផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពី ច្បាប់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងការរីករាលដាល នៃមេរោគអេដស៏/ជំងឺអេដស៏ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋនិងឯកជន និងតាមគ្រប់វិធានការដែលអាចធ្វើទៅបាន ។

២. ត្រៀមចូលរួមធ្វើបទឧទ្ទេសនាមនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដល់និស្សិត ចំនួន ៣00 នាក់ នៅថ្ងៃទី0៨/៦/២០១១ ។

៣. ត្រៀមចូលរួមឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាលស្តីពីការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនពាក់ពន្ធ័នឹងវិស័យអប់រំ នាថ្ងៃទី២២ មិថុនា ឆ្នាំ២០១១ នៅសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង ។

៤. ត្រៀមចូលរួមក្នុងសិក្ខាសាលាអន្តរក្រសួង ដើម្បីផ្តល់ការណែនាំពីនីតិវិធីនៃការរៀបចំធាតុចូល សម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ ឆ្នាំ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) បច្ចុប្បន្នកម្ម២០0៩-២០១៣ ដែលរៀបចំដោយក្រសួងផែនការនាថ្ងៃទី0២-0៣/៦/២០១១ ។

៥. អាជ្ញាធរជាតិ(អ.ជ.ប.គ.ញ) នឹងត្រៀមប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១១ នៅខេត្តគោលដៅចំនួន ៧ គឺ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្ត កំពង់ចាម ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងធ្វើការណែនាំដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តដទៃទៀតឱ្យប្រារព្ធទិវានេះ ជាពិសេស នៅតាមតំបន់គោលដៅដែលងាយប្រឈមខ្ពស់នឹងខ្ពស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

៦. ត្រៀមបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ ដល់មន្ត្រីអនុវត្តច្បាប់ នៅខេត្តកំពង់ចាម ថ្ងៃទី១៥-១៧/៦/២០១១ ។

៧. ត្រៀមលក្ខណៈសម្បត្តិចុះក្តាប់សភាពការណ៍ និងពង្រឹងការងារ នៅតាមគ្រប់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចាប់ពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១១ រហូតចប់បេសកកម្ម ។

៨. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងធ្វើការបូកសរុប ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាអំពីលទ្ធផលបឋមពាក់ពន្ធ័នឹងដំណើរការចុះសិក្សាស្រាវជ្រាវ ប្រមែប្រមូលទិន្នន័យព័ត៌មានពាក់ពន្ធ័នឹងការគ្រប់គ្រង ការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ នៅខេត្តស្វាយរៀង ។

៩. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តចុះសិក្សាស្រាវជ្រាវ ប្រមែប្រមូលទិន្នន័យព័ត៌មានពាក់ពន្ធ័នឹងការគ្រប់គ្រង ការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំនៅខេត្តកំពង់ចាម ។

១០. អ.ជ.ប.គ.ញ នឹងបន្តកិច្ចសហប្រតិបត្តិការរៀបចំផែនការសកម្មភាពគម្រោង កម្ពុជា-កូរ៉េ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (រយៈពេលវែង) ។

១១. ស្នើសុំគោលការណ៍ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីដាក់ការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅច្រកទ្វារអន្តរជាតិភ្នំដិន(ខេត្តតាកែវ) និងច្រកទ្វារអន្តរជាតិត្រពាំងផ្លុង(ខេត្តកំពង់ចាម) ។

១២. ត្រៀមចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ២រូប និងសម្របសម្រួលជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នូវមន្ត្រី ១រូប ទៅចូលរួមសិក្ខាសាលាស្តីពីគ្រឿងញៀន និង ហ៊ីវ/អេដស៍ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នាថ្ងៃទី១៤-១៨ ខែមិថុនា ឆ្នាំ២០១១ ។

១៣. ត្រៀមចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចំនួន៣រូប ទៅចូលរួមវេទិកាសម្របសម្រួលនិងទំនាក់ទំនងរបស់

កម្មវិធី HAARP ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី២៧-២៩ខែមិថុនាឆ្នាំ២០១១ នៅទីក្រុងលួងប្រាបាង ប្រទេសឡាវ ។

ក្រៅពីការអនុវត្តន៍ទិសដៅខាងលើ អាជ្ញាធរជាតិ( អ.ជ.ប.គ.ញ) នឹងបន្តជំរុញការងារមួយចំនួនដូចខាងក្រោម :

- បន្តអនុវត្តអនុសាសន៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផល និងដកពិសោធន៍ការអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ ។
- បន្តអនុវត្តតាមអនុសាសន៍ណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ លេខ០៤/២០១១/សណន និង អនុសាសន៍ណែនាំ លេខ០៦/២០១១/សណន ដែលនៅសេសសល់មួយចំនួន ។
- សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជំរុញការរៀបចំបង្កើតក្រុមការងារអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៃបណ្តាខេត្តនៅភាគឦសានប្រទេស ។
- បន្តការរៀបចំយន្តការបង្កើត "សាលារៀនពណ៌បៃតង គ្មានគ្រឿងញៀន" ។
- បន្តការរៀបចំផែនការជាតិ៥ឆ្នាំ (១០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ត្រៀមចូលរួមក្នុងសិក្ខាសាលាអន្តរក្រសួង ដើម្បីផ្តល់ការណែនាំពី នីតិវិធីនៃការរៀបចំធាតុចូល សម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិឆ្នាំ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ( ផ.យ.អ.ជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣ (០២-០៣/៦/២០១១ នៅខេត្តសៀមរាប ។
- បន្តកិច្ចសហការជាមួយក្រសួងផែនការ ជំរុញការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀនថ្នាក់ជាតិ ។
- បន្តអនុវត្តការប៉ាន់ប្រមាណពីចំនួនអ្នកប្រើគ្រឿងញៀននៅកម្ពុជា ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អជបគញ
-ក្រសួងផែនការ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ

## ការងារផ្សព្វផ្សាយអប់រំអំពី
## ច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ខែឧសភា ឆ្នាំ២០១១

| ឈ្មោះ<br>អង្គភាពសាមី | ឈ្មោះអង្គភាព<br>សហការសំរបសំរួល | ខ្លឹមសារផ្សព្វផ្សាយ គោលដៅ សមាសភាព | ចំនួនអ្នក<br>ចូលរួម |
|---|---|---|---|
| ក្រសួងអប់រំយុវជន<br>និងកីឡា | អជបគញ | -ការផ្តល់កិច្ចសម្ភាសន៍ នៅស្ថានីយទូរទស្សន៍ ស៊ីធីអិន<br>ក្រោមប្រធានបទស្តីពីការទទួលខុសត្រូវក្នុងការអប់រំ និងបង្ការបញ្ហាពីផលប៉ះពាល់<br>និងឥទ្ធិពលគ្រឿងញៀន (ដោយក្រសួងអប់រំយុវជន និងកីឡា) | |
| ន.ប ខេត្តកំពង់ធំ | | -ផ្សព្វផ្សាយច្បាប់ និងផលប៉ះពាល់នៃគ្រឿងញៀន នៅស្រុកបារាយណ៍ និងស្រុកសន្ទុក<br>៩លើក(២.៨២២ នាក់/ស្រី១.៤៦២ នាក់)<br>-ចុះបង្រឹងវិធានការអនុវត្តច្បាប់គ្រឿងញៀន ៨លើក មានគណៈអភិបាលក្រុង ស្រុក អធិការ<br>អធិការរង ស្រុក ក្រុង ចៅសង្កាត់ ន.ប ប៉ុស្តិ៍<br>នាយកសាលា មន្ត្រីការិយាល័យជំនាញស្រុក (៥៥០ នាក់/ស្រី៣៦ នាក់) | ៣.៣៧២ នាក់ |
| តំបន់ប្រតិបត្តិការ<br>សឹករងកំពង់ធំ | | -ផ្សព្វផ្សាយគ្រោះថ្នាក់នៃគ្រឿងញៀន ដល់នាយទាហាន ៣លើក= (១៥២នាក់/ស្រី៨នាក់) | ១៥២ នាក់ |
| អាជ្ញាធរស្រុក<br>សណ្តាន់ សន្ទុក<br>(កំពុងធំ) | | -ផ្សព្វផ្សាយច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ៥ លើក (១១១៣ នាក់/ស្រី ៣៥៩ នាក់ | ១.១១៣នាក់ |
| លេខាធិការដ្ឋាន<br>គ.ញ ប៉ៃលិន | -អង្គការ CHED<br>-សមាគមនារីកម្ពុជា<br>ដើម្បីសន្តិភាពនិង<br>អភិវឌ្ឍន៍ | -ផ្សព្វផ្សាយផលប៉ះពាល់នៃ គ.ញ ស/ក ប៉ៃលិន អូតាវ៉ៅ បយ៉ាខា ឃុំស្ទឹងកាច់ ឃុំអូរអណ្តូង<br>(២៥២ នាក់)។ នៅភូមិស្ទួនអំពៅ ភូមិបហ៊ុយខាងជើង ភូមិបតាំងស៊ូ សង្កាត់បយ៉ាខា -<br>ភូមិផ្សារព្រំ ភូមិអូរអិល ភូមិអូរឈើក្រំ ឃុំស្ទឹងកាច់ - ភូមិអូរជ្រើស សង្កាត់អូរតាវ៉ៅ ៣០៤ នាក់<br>-ផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍ សុខភាពបន្តពូជ និងកាមរោគ<br>នៅតាមកាស៊ីណូ ផ្ទះសំណាក់ ខារ៉ាអូខេ ក្នុងក្រុង<br>ប៉ៃលិន ២២កន្លែង= (១៥៥ នាក់) + ២០កន្លែង នៅក្រុងប៉ៃលិន ២៨៣ នាក់ | ៩៩៤ នាក់ |
| ន.ប ស្រុកដំណាក់<br>ចង្អើរ ខេត្តកែប | | -ផ្សព្វផ្សាយច្បាប់គ្រោះថ្នាក់នៃគ្រឿងញៀន<br>តាមរយៈកម្មវិធីនគរបាលប៉ុស្តិ៍ជួបជាមួយប្រជាពលរដ្ឋស្តីពី ការចាត់តាំងអនុវត្ត គោលនយោ<br>បាយ ភូមិ ឃុំមានសុវត្ថិភាព នៅភូមិអង្កោល (១៥៥ នាក់/ស្រី ៨២ នាក់) | ១៥៥ នាក់ |
| ន.ប ក្រុងកែប<br>ខេត្តកែប | | -ផ្សព្វផ្សាយច្បាប់គ្រោះថ្នាក់នៃគ្រឿងញៀន<br>តាមរយៈកម្មវិធីនគរបាលប៉ុស្តិ៍ជួបជាមួយប្រជាពលរដ្ឋស្តីពី ការចាត់តាំងអនុវត្ត គោលនយោ<br>បាយ ភូមិ ឃុំមានសុវត្ថិភាព នៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ (២៤ នាក់/ស្រី ៧ នាក់) | ២៤ នាក់ |
| អាជ្ញាធរក្រុងក្រ<br>ចេះ ស្រុកសំបូរ<br>ស្រុកព្រែកប្រសព្វ | | -ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍ នៅតាមគ្រួសារ និងសហគមន៍<br>២៥លើក=(២៩៧ នាក់/ស្រី១៣៩ នាក់)<br>-ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ<br>គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព នៅឃុំសណ្តាន់<br>ស្រុកសំបូរ (៨៣ នាក់/ស្រី ៣៤ នាក់)<br>-ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន បញ្ហាអេដស៍<br>ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរនៅឃុំព្រែកប្រសព្វ(១០០ នាក់/ស្រី ៦០ នាក់) | ៤៨០ នាក់ |
| -ក្រុងព្រះវិហារ<br>-ស្រុកត្បែងមាន<br>ជ័យ | អង្គការទស្សនៈ<br>ពិភពលោក | -ផ្សព្វផ្សាយច្បាប់គ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈការប្រគំតន្ត្រីខ្នាតធំនៅពហុកីឡាដ្ឋានខេត្ត<br>ក្នុងភូមិអណ្តូងពោធិ សង្កាត់កំពង់ប្រណាក<br>ក្រុងព្រះវិហារ ៣ថ្ងៃ (២០០០០ នាក់/ស្រី ១៤៦៩២ នាក់)<br>-ផ្សព្វផ្សាយច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀននៅភូមិពោធិខឿន ស្រឡៅទូង ស្រែព្រាង បុស្សធំ<br>ឃុំប្រមេ (៥៤៦ នាក់/ស្រី ៣៥៤ នាក់) | ២០.៥៤៦ នាក់ |
| អាជ្ញាធរក្រុងព្រះ<br>វិហារ - ស្រុកឆែប | | -ផ្សព្វផ្សាយច្បាប់គ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ៨លើក (៣១៤៤ នាក់/ស្រី ១៣១១ នាក់) | ៣.១៤៤ នាក់ |
| | | **សរុប** | ២៩.៩៨០ នាក់ |

# អង្គភាពបង្ក្រាបបទល្មើសគ្រឿងញៀន ក្នុងខែឧសភា ឆ្នាំ២០១១

| ល.រ | អង្គភាព | សរុបរួម | | | ផលិតចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| 1 | មន្ទីរប្រឆាំងគ្រឿងញៀន | **5** | **17** | **4** | 5 | 17 | 4 | | | | | | |
| 2 | ន.ដ្ឋាន កណ្តាល សន្តិសុខ | **2** | **7** | **3** | 2 | 7 | 3 | | | | | | |
| 3 | ន.ប ភ្នំពេញ | **28** | **68** | **8** | 23 | 52 | 7 | 5 | 16 | 1 | | | |
| 4 | ន.ប កណ្តាល | **8** | **20** | **4** | 4 | 6 | 1 | 4 | 14 | 3 | | | |
| 5 | ន.ប តាកែវ | **4** | **5** | **0** | 4 | 5 | 0 | | | | | | |
| 6 | ន.ប កំពង់ស្ពឺ | **2** | **3** | **0** | 2 | 3 | 0 | | | | | | |
| 7 | ន.ប កំពង់ឆ្នាំង | **0** | **2** | **0** | | | | | | | 0 | 2 | 0 |
| 8 | ន.ប កំពង់ចាម | **19** | **67** | **13** | 15 | 46 | 9 | 4 | 16 | 3 | 0 | 5 | 1 |
| 9 | ន.ប ព្រះសីហនុ | **3** | **6** | **3** | 2 | 5 | 3 | 1 | 1 | 0 | | | |
| 10 | ន.ប សៀមរាប | **30** | **94** | **20** | 7 | 23 | 9 | 23 | 71 | 11 | | | |
| 11 | ន.ប ព្រៃវែង | **3** | **6** | **4** | 3 | 6 | 4 | | | | | | |
| 12 | ន.ប ស្ទឹងត្រែង | **3** | **5** | **0** | 3 | 3 | 0 | | | | 0 | 2 | 0 |
| 13 | ន.ប រតនគីរី | **2** | **3** | **2** | 2 | 3 | 2 | | | | | | |
| 14 | ន.ប កំពត | **1** | **1** | **0** | 1 | 1 | 0 | | | | | | |
| 15 | ន.ប បាត់ដំបង | **29** | **50** | **11** | 28 | 49 | 11 | 1 | 1 | 0 | | | |
| 16 | ន.ប កោះកុង | **1** | **1** | **0** | 1 | 1 | 0 | | | | | | |
| 17 | ន.ប បន្ទាយមានជ័យ | **9** | **22** | **8** | 8 | 18 | 4 | 1 | 4 | 4 | | | |
| 18 | ន.ប កំពង់ធំ | **2** | **6** | **2** | 2 | 6 | 2 | | | | | | |
| 19 | ន.ប ក្រចេះ | **2** | **6** | **0** | 1 | 2 | 0 | 1 | 4 | 0 | | | |
| 20 | ន.ប មណ្ឌលគីរី | **3** | **5** | **1** | 3 | 5 | 1 | | | | | | |
| 21 | ន.ប ប៉ៃលិន | **2** | **2** | **0** | 1 | 1 | 0 | 1 | 1 | 0 | | | |
| 22 | ន.ប ឧត្តរមានជ័យ | **4** | **13** | **4** | 4 | 13 | 4 | | | | | | |
| **សរុប** | | **162** | **409** | **87** | **121** | 272 | 64 | **41** | 128 | 22 | **0** | 9 | 1 |

# វត្ថុតាងចាប់យក ក្នុងខែឧសភា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | **WY** (គ្រាប់) | **ICE** (ក្រាម) | **Heroine** (ក្រាម) | ដើមកញ្ឆា ម² | កញ្ឆាក្រៀម (ក្រាម) | **Ecstasy** (គ្រាប់) | **Pseudo-Ephedrine** | សារធាតុផ្សំ គ្រ.ញ | ប្រេងម្រះព្រៅភ្នំ |
| **1** | មន្ទីរប្រឆាំងគ្រឿងញៀន | | *415,2* | | | | *1.346* | | | |
| **2** | ន.ដ្ឋាន កណ្តាលសន្តិសុខ | *12* | *1,4* | *1.000* | | | | | *51,6 Kg+ 23 L* | |
| **3** | ន.ប ភ្នំពេញ | *9* | *95,69* | *0,45* | | | *17* | | | |
| **4** | ន.ប កណ្តាល | | *5,92* | | | | | | | |
| **5** | ន.ប តាកែវ | | *1,6* | | *1212 ដើម* | | | | | |
| **6** | ន.ប កំពង់ស្ពឺ | *4* | *3* | | | *200 Kg* | | | | |
| **7** | ន.ប កំពង់ចាម | *26* | *46,55* | | | | | | | |
| **8** | ន.ប ព្រះសីហនុ | | *8,1* | | | | | | | |
| **9** | ន.ប សៀមរាប | *91* | *1,56* | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| *10* | ន.ប ព្រៃវែង | *167* | *1,06* | | | | | | | |
| *11* | ន.ប ស្ទឹងត្រែង | *1.515* | *0,15* | | | | | | | |
| *12* | ន.ប រតនគីរី | *17* | | | | | | | | |
| *13* | ន.ប កំពត | | | | *1770* ដើម | | | | | |
| *14* | ន.ប បាត់ដំបង | *766* | *35,1* | | *1000* ដើម | | | | | |
| *15* | ន.ប កោះកុង | *36* | | | | | | | | |
| *16* | ន.ប បន្ទាយមានជ័យ | *163* | *0,5* | | | | | | | |
| *17* | ន.ប កំពង់ធំ | | *0,82* | | | | | | | |
| *18* | ន.ប ក្រចេះ | | *7,9* | | | | | | | |
| *19* | ន.ប មណ្ឌលគីរី | *28* | *3,82* | | | | | | | |
| *20* | ន.ប ប៉ៃលិន | *18* | | | | | | | | |
| *21* | ន.ប ឧត្តរមានជ័យ | *364* | *0,32* | | | | | | | |
| | សរុប | ***3.216*** | ***628,69*** | ***1.000,45*** | ***3.982*** ដើម | ***200 Kg*** | ***1.363*** | | ***51,6 Kg+ 23 L*** | |

**វត្ថុតាងផ្សេងៗ ៖**

1-មន្ទីរប្រឆាំង គ្រ.ញ ជញ្ជីង១, រថយន្ត ១គ្រឿង, ម៉ូតូ ១ គ្រឿង , កាំភ្លើងខ្លី ១

2-នាយកដ្ឋានកណ្តាលសន្តិសុខ ជញ្ជីង៣, ឧបករណ៍ផលិត គ្រ.ញ មួយចំនួន, លុយ ២.៩០០ ដុល្លារ, ៦.៧០០.០០០ ដុង, ១៣០.០០០ រៀល, ៥០ បាត ។

3-ន.ប ភ្នំពេញ ម្សៅពណ៌ ស = ០,០៧ ក្រាម, ម្សៅពណ៌ ផ្កាឈូក ០,០៤ ក្រាម, ជញ្ជីង៣, ពុម្ព៣, ម៉ូតូ ១០, កង់១, កាំភ្លើងខ្លី២, លុយ ៣៧៣០ ដុល្លារ, ១០០០យន់ និង ១.២៤០.០០០ ដុង

4-ន.ប កណ្តាល ម៉ូតូ២, កាំភ្លើងវែង១

5-ន.ប តាកែវ លុយ ១.១០០.០០០ រៀល និង ៤១ ដុល្លារ

6-ន.ប កំពង់ស្ពឺ លុយ ១.១០០.០០០ រៀល និង ៤១ ដុល្លារ

7-ន.ប កំពង់ចាម ម៉ូតូ ៩, កង់១

8-ន.ប ព្រះសីហនុ រថយន្ត១, ម៉ូតូ ១, លុយ ១២ ដុល្លារ, ១០ ដុល្លារហុងកុង, ១០០០ យន់

9-ន.ប ព្រៃវែង លុយ ៧០.០០០ រៀល

10-ន.ប ស្ទឹងត្រែង ម៉ូតូ ២, លុយ ១៤.០០០.០០០ រៀល

11-ន.ប រតនគីរី ម៉ូតូ ១

12-ន.ប បាត់ដំបង ម៉ូតូ ២, លុយ ១.២៨៣.៤០០ រៀល និង ៤៥០ បាត

13-ន.ប កោះកុង ម៉ូតូ ១, លុយ ៤២០.០០០ រៀល, ៣៣ ដុល្លារ និង ២០ បាត

14-ន.ប បន្ទាយមានជ័យ ម៉ូតូ ១, លុយ ៤៥.៥០០ រៀល និង ៦២៣ បាត

15-ន.ប មណ្ឌលគីរី ម៉ូតូ ១, រថយន្ត១

16-ន.ប ឧត្តរមានជ័យ ទូរសព្ទ័ ៧, រថយន្ត១, ម៉ូតូ២

## ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូល ប្រចាំខែ ឧសភា ឆ្នាំ ២០១១

| ឈ្មោះសារធាតុគីមី | ការផ្តល់អាជ្ញាបណ្ណ័ ដោយក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | | | ការផ្តល់អាជ្ញាបណ្ណ័ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Xylene | 89.982 | | | | | | **89.982** | | |
| Sulphuric Acid | 1.306.000 | | | | | | **1.306.000** | | |
| Caustic Soda | 100.000 | | | 64.000 | | | **164.000** | | |
| Toluene | 231.993 | | | 12.000 | | | **243.993** | | |
| Ethyl Acetate | 35.000 | | | | | | **35.000** | | |
| Soda Ash | 150.000 | | | 312.000 | | | **462.000** | | |
| Hydrochloric Acid | 30.000 | | | | | | **30.000** | | |
| Acetic Acid Glacial | 20.000 | | | 43.000 | | | **63.000** | | |
| Acetic Acid | 3.000 | | | 50.000 | | | **53.000** | | |
| Acetone | 52.000 | | | 2.000 | | | **54.000** | | |
| Methyl Ethyl Ketone | 25.500 | | | 13.000 | | | **38.500** | | |
| Sodium Sulfate | | | | 714.000 | | | **714.000** | | |
| Formic Acid | | | | 19.000 | | | **19.000** | | |
| Methylene Chloride | | | | 9.150 | | | **9.150** | | |
| Solvent | | | | 9.000 | | | **9.000** | | |
| Total | **2.043.475** | | | **1.247.150** | | | **3.290.625** | | |